អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

Kampuchea Action to Promote Education (KAPE)

គម្រោង សម្ពន្ធភាពដើម្បីការអភិវឌ្ឍ ប្រកបដោយចេរភាព និងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម CO-SAVED (ខូសេវ) មានរយៈពេលអនុវត្ត ៤ឆ្នាំ (២០២១-២០២៤) ចំនួន០៤ខេត្តនៅជាប់តំបន់ឆ្នេរសមុទ្រ គឺ កំពត កែប ព្រះសីហនុ និងកោះកុង។ គម្រោងនេះចូលរួមពីស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ដោយ វិនិយោគលើវិស័យអប់រំ ទឹកស្អាត និង អនាម័យ បរិស្ថាន ថាមពល និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ គោលដៅរួមរបស់គម្រោង៖ សហគមន៍នេសាទក្នុងតំបន់ឆ្នេរសមុទ្រប្រែក្លាយមានភាពរស់រវើកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយចេរភាព ពង្រឹងនូវការផ្តល់សេវាកម្ម និងការអភិវឌ្ឍបៃតង សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងវិសមភាព។

- អភិវឌ្ឍសមត្ថភាព និងពង្រឹងភាពជាដៃគូ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅកម្រិតមូលដ្ឋាន។
- ពង្រឹងនូវការផ្តល់សេវា អប់រំនិងការទទួលបានទឹកស្អាត និងអនាម័យ។
- ពង្រឹងការផ្តល់ឱកាសសម្រាប់ការប្រកបមុខរបរ ចិញ្ចឹមជីវិត និងការអភិរក្ស ដើម្បីអភិវឌ្ឍសេចដ្ឋកិច្ចនៅមូលដ្ឋាន។

ដូច្នេះគម្រោងត្រូវការជ្រើសរើសអាជីវករដើម្បីផ្គត់ផ្គង់កង់ជជុះមួយទឹករបស់ប្រទេសជប៉ុនផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សមធ្យមសិក្សាតាមសាលារៀនគោលដៅក្នុងខេត្ត កោះកុង ចំនួន ០៣ស្រុក គឺស្រុក ស្រែអំបិល, ស្រុក បទុមសាគរ និងស្រុក គិរីសាគរ តាមការណែនាំដូចខាងក្រោម៖

**ក. លក្ខខ័ណ្ឌ៖**

១. អាជីវករ ត្រូវមានបទពិសោធន៍ក្នុងការផ្គត់ផ្គង់ជជុះមួយទឹករបស់ប្រទេសជប៉ុន ដែលជាសម្ភារ អាហារូបករណ៍សិស្សានុសិស្សកន្លងមកដល់អង្គការ ឬក្រុមហ៊ុនផ្សេងៗ។

២. អាជីវករ ត្រូវបំពេញ និងដាក់ពាក្យសុំចូលរួមដេញថ្លៃមកអង្គការមុនថ្ងៃធ្វើការដេញថ្លៃតាមកាលបរិច្ឆេទកំណត់របស់អង្គការដែលបានប្រកាសជ្រើសរើសអ្នកផ្គត់ផ្គង់។

៣. អាជីវករ ត្រូវចូលរួមបើកឯកសារសម្រង់តម្លៃ ដែលប្រព្រឹត្តិទៅតាមរយៈអនឡាញ ឬក៏អញ្ជើញចូលរួមដោយផ្ទាល់នៅការិយាល័យរបស់អង្គការ ខេប ដែលមានអាសយដ្ឋាន ភូមិពងទឹក ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០នាទី ព្រឹកជាកំហិតដោយខានមិនបាន។

៤. អាជីវករ ត្រូវគោរពតាមគោលការណ៍ណែនាំរបស់អង្គការ និងគម្រោង។

៥. អាជីវករ ត្រូវដឹកជញ្ជូនដល់គោលដៅនីមួយៗនៃខេត្ត កោះកុង ដោយដាក់នៅការិយាល័យអប់រំយុវជន និងកីឡាស្រុក ស្រែអំបិល, ស្រុក បទុមសាគរ និងស្រុក គិរីសាគរ។

• *Head Offices: Provincial Teacher Training College of Kampong Cham Kampong Cham Town, Kampong Cham Province.*
• *Mailing Address: PO Box1621, Post Office, P. Penh. Tel.: 042-941-481, 042- 941-918; E-mail: kape@kapekh.org; www.kapekh.org*

## ខ. តារាងព័ត៌មានលម្អិតពីសម្ភារដែលអង្គការ/គម្រោងត្រូវការ៖

| ឈ្មោះទំនិញ (អធិប្បាយ) | ចំនួនសម្ភារ | រូបភាព |
|---|---|---|
| **កង់របស់សិស្ស**<br>(មានរូបសញ្ញាអង្គការ) | **កង់** | |
| កង់ជជុះមួយទឹកសម្រាប់សិស្ស<br>នៅអនុវិទ្យាល័យចំនួន៖១២០នាក់<br>(វង្ង់កង់លេខ២៧)<br>(ក្នុងម្នាក់ចំនួន៖០១គ្រឿង)<br>សម្រាប់ខេត្ត កោះកុង | **១២០គ្រឿង** | <br> |
| **សរុប** | **១២០គ្រឿង** | |

| ស្រុក | កម្រិតថ្នាក់ | ចំនួនសិស្ស | | សរុប | |
|---|---|---|---|---|---|
| ស្រែអំបិល | ថ្នាក់ទី៧-៩ | សិស្សប្រុស | ៤៧ | ៩៥ | **កង់ជជុះជប៉ុនវង្ង់ លេខ២៧** |
| | | សិស្សស្រី | ៤៨ | | |
| បូទុមសាគរ | | សិស្សប្រុស | ៦ | ១២ | |
| | | សិស្សស្រី | ៦ | | |
| គិរីសាគរ | | សិស្សប្រុស | ៦ | ១៣ | |
| | | សិស្សស្រី | ៧ | | |

**ចំណាំ៖ កង់របស់សិស្ស**

១. គុណភាព ៖ អាជីវករ ត្រូវតែធានាថាជាកង់ជជុះរបស់ជប៉ុន១០០%។

២. ទំហំ៖ អាជីវករ ត្រូវតែធានាថាត្រឹមត្រូវតាមលក្ខខណ្ឌដែលយើងចង់បានដូចខាងលើ។

• *Head Offices: Provincial Teacher Training College of Kampong Cham Kampong Cham Town, Kampong Cham Province.*
• *Mailing Address: PO Box1621, Post Office, P. Penh. Tel.: 042-941-481, 042- 941-918; E-mail: kape@kapekh.org; www.kapekh.org*